# តើប្រព័ន្ធបោះឆ្នោតថ្មីដំណើរការទៅយ៉ាងដូចម្តេច ?

ក្រុមប្រឹក្សាក្រុង៖ អ្នកបោះឆ្នោតនឹងជ្រើសរើសបេក្ខជនមួយរូប ពីសង្កាត់ដែលពួកគេរស់នៅ ដើម្បីអោយបម្រើនៅក្នុងក្រុមប្រឹក្សាក្រុង។ លើសពីនេះ អ្នកបោះឆ្នោតក៏នឹងជ្រើសរើសបេក្ខជនតំណាងសង្កាត់ទាំងអស់ចំនួន ៣ រូប ដែលអាចមកពីតំបន់ណាមួយនៃទីក្រុងក៏បាន។

គណៈកម្មាធិការសាលា៖ អ្នកបោះឆ្នោតនឹងជ្រើសរើសបេក្ខជនមួយរូបពីសង្កាត់របស់ពួកគេ និងបេក្ខជនតំណាងសង្កាត់ទាំងអស់ចំនួន 2 រូបទៀត។ សង្កាត់ទាំងនេះត្រូវបានបង្កើតឡើងដោយការដាក់បញ្ចូលគ្នានូវសង្កាត់ពីរៗ ក្នុងចំណោមសង្កាត់ដែលមានតំណាងក្រុមប្រឹក្សាក្រុងថ្មីទាំង ៨។

សង្កាត់របស់តំណាងគណៈកម្មាធិការសាលាលេខ 1 កើតឡើងពីការបញ្ចូលគ្នារវាងសង្កាត់របស់តំណាងក្រុមប្រឹក្សាក្រុង លេខ 1 និង លេខ 8
សង្កាត់របស់តំណាងគណៈកម្មាធិការសាលាលេខ 2 កើតឡើង ពីការបញ្ចូលគ្នារវាងសង្កាត់របស់តំណាងក្រុមប្រឹក្សាក្រុង លេខ 4 និង លេខ 2
សង្កាត់របស់តំណាងគណៈកម្មាធិការសាលាលេខ 3 កើតឡើង ពីការបញ្ចូលគ្នារវាងសង្កាត់របស់តំណាងក្រុមប្រឹក្សាក្រុង លេខ 3 និង លេខ 5
សង្កាត់របស់តំណាងគណៈកម្មាធិការសាលាលេខ 4 កើតឡើង ពីការបញ្ចូលគ្នារវាងសង្កាត់របស់តំណាងក្រុមប្រឹក្សាក្រុង លេខ 6 និង លេខ 7



## តើយើងជានរណា ?

យើងគឺជាដៃគូរវាងអង្គការសហគមន៍និងប្រជាជននៅទីក្រុងឡូវែល។ គោលដៅរបស់យើងគឺដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីប្រព័ន្ធបោះឆ្នោតថ្មី និងជំរុញអោយប្រជាជន មានការចូលរួមក្នុងដំណើរការបោះឆ្នោតថ្នាក់មូលដ្ឋាន។

LOWELL LINES + LOWELL VOTES

# សេចក្តីណែនាំអំពីប្រព័ន្ធបោះឆ្នោតថ្មីរបស់ទីក្រុងឡូវែល

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ lowellvotes.org

# ហេតុអ្វីបានជាប្រព័ន្ធបោះឆ្នោត នៅទីក្រុងឡូវែលមានការផ្លាស់ប្តូរ ?

ប្រព័ន្ធបោះឆ្នោតថ្មីនៅទីក្រុងឡូវែលដែលចូលជាធរមាននៅឆ្នាំ 2021 គឺជាលទ្ធផលនៃបណ្តឹងទាក់ទងនឹងសិទ្ធិបោះឆ្នោត ( Voting Rights Act ) ដែលបានប្តឹងតវ៉ានឹងទីក្រុងនេះ។ ពាក្យបណ្តឹងដែលត្រូវបានដោះស្រាយនៅឆ្នាំ 2019 បានអះអាងថា ប្រព័ន្ធបោះឆ្នោតជ្រើសរើសបេក្ខជនដែលតំណាងសង្កាត់ទាំងអស់ មានភាពអយុត្តិធម៌ចំពោះអ្នកបោះឆ្នោតដែលជាជនជាតិភាគតិច ( *BIPOC ) និងបង្កើតវិសមភាពនៅក្នុងទីក្រុងឡូវែល។ នៅឆ្នាំមុនៗកន្លងមកនេះ ក្រុមប្រឹក្សាក្រុងនឹងគណៈកម្មាធិការសាលារបស់ក្រុងឡូវែលត្រូវបានជ្រើសរើសតាមលក្ខណៈបេក្ខជនដែលតំណាងអោយសង្កាត់ទាំងអស់, ជាមួយនឹងចំនួនកៅអីទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសដោយទីក្រុងទាំងមូល។ ឥឡូវនេះ ក្រុមប្រឹក្សាក្រុងនិងគណៈកម្មាធិសាលានឹងត្រូវបានជ្រើសរើសចេញពីសង្កាត់នីមួយៗ ដែលត្រូវបានបង្កើតឡើងនៅរដូវស្លឹកឈើជ្រុះឆ្នាំ 2020, ជាមួយនឹងសង្កាត់ចំនួន 2 ក្នុងចំណោមសង្កាត់ទាំង 8 ដែលបង្កើតឡើងដោយមានប្រជាជនភាគច្រើនជាជនជាតិភាគតិច ។ ការផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតនេះ មានគោលបំណងដើម្បីធានា ឱ្យមានរដ្ឋាភិបាលដែលមានអ្នកតំណាងពីជាតិសាសន៍ផ្សេងៗកាន់តែច្រើន តាមរយៈការជ្រើសរើសបេក្ខជន ដែលរស់នៅគ្រប់តំបន់នៃទីក្រុងឡូវែល។

*ជនជាតិស្បែកខ្មៅ ជនជាតិដើម និងជនជាតិដែលមានពណ៌សម្បុរផ្សេងទៀត

# តើធ្វើដូចម្តេចទើបខ្ញុំអាចដឹងថាខ្ញុំស្ថិតនៅក្នុងសង្កាត់មួយណា ?




## កំណត់សម្គាល់

- DISTRICT 1: ផធឹកយែតវីល
- DISTRICT 2: សិនត្រលវីល
- DISTRICT 3: បែលវីខែរ, សោហ្វ ឡូវែល, ឡូវើ បែលវីខែរ
- DISTRICT 4: ដោនថោន, ផធឹកយែតវីល, សិនត្រលវីល, ឌី អេកឹ, ប៊ែក សិនត្រល
- DISTRICT 5: សេក្រិត ហាត, សោហ្វ ឡូវែល
- DISTRICT 6 (MAJORITY MINORITY): ឡូវើ ហាយលែនស៍, ហាយលែនស៍
- DISTRICT 7 (MAJORITY MINORITY): ឌី អេកឹ, ឡូវើ ហាយលែនស៍, ហាយលែនស៍
- DISTRICT 8: ហាយលែនស៍

ដើម្បីមើលផែនទីឌីជីថល ដែលលោកអ្នកអាចស្វែងរកអាសយដ្ឋានមួយៗបាន សូមចូលទៅគេហទំព័រ៖ yourlowellyourvote.org

ផែនទីសង្កាត់ដែលបានស្នើបង្កើតឡើង ត្រូវបានផ្សព្វផ្សាយចេញនៅខែវិច្ឆិកា ឆ្នាំ2020, ដោយបន្ទាប់មកត្រូវបានដាក់អោយសាធារណៈជនផ្តល់មតិយោបល់អស់រយៈពេល 2 ខែ ដែលក្នុងកំឡុងពេលនោះការប្រជុំផ្សព្វផ្សាយពត៌មានដល់សាធារណៈជនជាច្រើន ក៏បានធ្វើឡើង ហើយប្រជាជនត្រូវបានលើកទឹកចិត្តឱ្យចែករំលែកមតិយោបល់របស់ពួកគេទៅលើសង្កាត់ទាំងនោះ។ ការខិតខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើង ដើម្បីរក្សាតំបន់រស់នៅមួយចំនួនអោយនៅជាមួយគ្នានៅក្នុងសង្កាត់នីមួយៗ ប៉ុន្តែដោយសារតែតម្រូវការក្នុងការធ្វើអោយសង្កាត់នីមួយៗមានចំនួនប្រជាជនប្រហាក់ប្រហែលគ្នា តំបន់រស់នៅខ្លះត្រូវបានបែងចែក ឬដាក់បញ្ចូលគ្នានៅក្នុងផែនទីសង្កាត់ដែលសំរេចចុងក្រោយ។